# មជ្ឈមណ្ឌលឯកសារកម្ពុជា

**បងប្រុសរបស់ ឡេង អាន់ ហៅ តា អាន់**

**បទសម្ភាសន៍ជាមួយ ឡេង អឿក អាយុ ៧៧ឆ្នាំ**

**ភូមិនមោ ឃុំដាងទោង ស្រុកត្រាំកក់ ខេត្តតាកែវ**

**ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១**

**សម្ភាសដោយ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា**

ដានី : លោកតាអីចឹងដំបូង ខ្ញុំចង់ស្គាល់ឈ្មោះលោកតា ឈ្មោះពេញ ឈ្មោះអីដែរលោកតា?

អឿក : ឡេង អឿក

ដានី : ឡេង អឿក? អាយុប៉ុន្មានហើយលោកតាសព្វថ្ងៃ?

អឿក : ៧៥-៧៦ ហើយឆ្នាំនេះ

ដានី : ៧៦ ឆ្នាំ ចុះលោកតា ឪពុកលោកតាឈ្មោះអីដែរ?

អឿក : ឈ្មោះ ដៃ

ដានី : ឈ្មោះ ដៃ? អីដៃទៅ?

អឿក : ឡេង ដៃ, ឡេង គឺជាជីតា ឪឪពុកខ្ញុំទៀតណា

ដានី : ចុះម្ដាយលោកតា?

អឿក : ឈ្មោះ ស៊ីវ

ដានី : អីស៊ីវទៅ?

អឿក : ជាវ ស៊ីវ

ដានី : បាទ!

អឿក : ជាវ ស៊ីវ ឪពុកគាត់ឈ្មោះ ជាវ

ដានី : ចុះលោកតាមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

អឿក : មាន ១១នាក់

ដានី : មានបងប្អូន ១១ នាក់? លោកតាអាចជួយរៀបរាប់ពីបងទី១ ទី២ឈ្មោះអីទៅលោកតា?

អឿក : បងទី១ឈ្មោះ ឡេង ទុំ

ដានី : ស្រីប្រុសឡេង ទុំ?

អឿក : ប្រុស

ដានី ៖ សព្វថ្ងៃគាត់នៅរស់ឬស្លាប់ហើយ?

អឿក ៖ ស្លាប់អស់ហើយ

ដានី ៖ ទី២?

អឿក ៖ ឡេង តុង ប្រុសទៀត

ដានី ៖ គាត់ស្លាប់ដែរ?

អឿក ៖ ស្លាប់

ដានី ៖ ទី៣?

អឿក ៖ ឡេង សឿន, ស្រី

ដានី ៖ គាត់នៅ ឬស្លាប់ដែរ?

អឿក ៖ ស្លាប់

ដានី ៖ ទី៤?

អឿក ៖ ឡេង ទក

ដានី ៖ ឡេង?

អឿក ៖ ឡេង ទក, ទ ដាក់ ក

ដានី ៖ គាត់ស្រី ឬប្រុស?

អឿក ៖ ប្រុស

ដានី ៖ នៅរស់ឬស្លាប់?

អឿក ៖ ស្លាប់

ដានី ៖ ទី៥?

អឿក ៖ ឡេង គីម, ស្រី

ដានី ៖ នៅរស់ឬស្លាប់?

អឿក ៖ ស្លាប់

ដានី ៖ ទី៦?

អឿក ៖ ខ្ញុំ, ឡេង អឿក

ដានី ៖ ទី៦ លោកតា?

អឿក ៖ បាទ

ដានី ៖ ចុះទី៧?

អឿក :   ទី៧ ឡេង អាន់

ដានី :   ឡេង?

អឿក :   ឡេង អាន់

ដានី :   គាត់ប្រុសឬស្រី?

អឿក :   ប្រុស

ដានី :   សព្វថ្ងៃគាត់នៅរស់?

អឿក :   ស្លាប់បាត់ហើយ

ដានី :   ស្លាប់ពីអង្កាល់ទៅ?

អឿក :   អត់ឃើញ ស្លាប់យូរហើយ តាំងពីបែកណោះ

ដានី :   ស្លាប់ហ្នឹងបានន័យថា គាត់ឈឺឬយ៉ាងម៉េច?

អឿក :   ហ្នឹងបែបឈឺ កាលហ្នឹងរត់ទៅបែកគ្នា មិនដឹងរត់ទៅណាទៅនៃអត់ជួបផង

ដានី :   អត់ជួប គ្រាន់តែបាត់ដំណឹងទេ?

អឿក :   បាទ បាត់រហូត, បាត់រហូតតែម្តង

ដានី :   យើងមិនដឹងថាគាត់ស្លាប់យ៉ាងម៉េចៗ តែគ្រាន់តែដឹងថាបាត់?

អឿក :   បាទ

ដានី :   ហ្នឹងប្អូនរបស់លោកតា?

អឿក :   ប្អូន

ដានី :   គាត់អាយុប៉ុន្មានដែរលោកតា?

អឿក :   ភ្លេចមួយទៀត ឡេង មាយ មួយទៀត ប្អូនបន្ទាប់ហ្នឹងទៀត

ដារ៉ា :   ឡេង មាយ ទីប៉ុន្មាន?

អឿក :   ទី៧

ដានី :   ឡេង មាយ ទី៧

អឿក :   ស្រី

ដានី :   ឡេង មាយ, ស្រី ៗ ចុះ មាយ គាត់នៅរស់ឬស្លាប់?

អឿក :   ស្លាប់, ទើបស្លាប់

ដារ៉ា :   នៅភូមិទទឹងថ្ងៃហ្នឹង?

អឿក :   បាទ ផ្ទះមួយ ផ្ទះថ្មហ្នឹង

ដានី ៖ ពីម្សិលខ្ញុំទៅផ្ទះគាត់ បានជួបកូនគាត់ឈ្មោះ មុំ

អឿក ៖ ទី៨?

ដានី ៖ មាយ អម្បាញ់មិញ គាត់អាយុប៉ុន្មានដែរ? លោកតា ៧៦ គាត់បន្ទាប់អាយុប៉ុន្មានដែរ?

អឿក ៖ ដក១ឆ្នាំកន្លះ ថា ៧៤ អីចឹងចុះ

ដានី ៖ ឡេង មាយ, ៧៤ គាត់កើតឆ្នាំអី?

អឿក ៖ ឆ្នាំ ជូត

ដានី ៖ ចុះ ឡេង អាន់?

អឿក ៖ ឆ្នាំអីទេ ប្អូនមាយហ្នឹងទៀតណា

ដានី ៖ ប្អូនមាយ ប្រហែលជាប្អូនប៉ុន្មានឆ្នាំ?

អឿក ៖ បងប្អូនខ្ញុំ ៣ឆ្នាំ២ ៗ

ដានី ៖ ចុះគាត់មានឈ្មោះអីផ្សេងទៀតដែរ?

អឿក ៖ អត់មានឈ្មោះផ្សេង

ដានី ៖ អត់មានដូរឈ្មោះអីផ្សេងទៀតទេ

អឿក ៖ បើខ្ញុំបានឈ្មោះច្រើន

ដារ៉ា ៖ ចុះឡេង អាន់ មានដូរឈ្មោះដូរអីដែរ?

អឿក ៖ អត់ទេ អត់មានដូរ

ដារ៉ា ៖ ដាក់ឡេង អាន់អីចឹងរហូត

អឿក ៖ បាទ

ដានី ៖ ទោះបីនៅក្នុងរបបបីឆ្នាំក៏ដោយ?

អឿក ៖ បែបគេឈ្មោះអីចឹង (សំឡេងអ្នកជិតខាង ៖ កាលណោះបាត់ពីគាត់ទៅក្រែងលគេដូរ គាត់អត់ដឹង កាលនៅមួយគាត់ដឹងឈ្មោះឡេង អាន់ ហ្នឹងតែម្តង បានថា យើងស្មានមិនត្រូវទេ ព្រោះបែកពីគាត់បាត់ហើយ)

ដានី ៖ ទី៩?

អឿក ៖ ទី៩ ឡេង មុំ

ដានី ៖ ស្រីឬប្រុស?

អឿក ៖ ស្រី

ដានី ៖ សព្វថ្ងៃគាត់នៅរស់ ឬស្លាប់?

អឿក : នៅ នៅ២ខ្ញុំឥឡូវ

ដានី : នៅរស់ ផ្ទះគាត់នៅឯណា? នៅភូមិនមោហ្នឹងដែរ?

អឿក : អត់ទេ នៅភូមិទទឹងថ្ងៃ

ដានី : ចុះទី១០?

អឿក : ឡេង ប៉ក់

ដានី : ឡេង ប៉ក់

អឿក : ហ្នឹង ពៅគេ

ដានី : ដប់នាក់ទេអីចឹង?

អឿក : ១១, ស្លាប់មួយអត់និយាយទេ

ដារ៉ា : ឡេង ប៉ក់នៅរស់ឬស្លាប់?

អឿក : ស្លាប់

ដានី : ចុះម្នាក់ទៀតស្លាប់ពីអង្កាល់?

អឿក : ស្លាប់ទើបកើតបានពីរបីខែណោះ .... អស់ហើយនែ ១១នែ

ដានី : ចុះបងប្អូនលោកទាំងប៉ុន្មានស្លាប់ ក្រៅពី ឡេង អាន់ គឺគាត់ស្លាប់នៅស្រុកនៅភូមិ..

អឿក : អត់ទេ បាត់តែម្តង មិនដឹងទៅណា .... ស្លាប់តាទក តាតុងស្លាប់នៅភូមិទេ បាត់មួយហ្នឹង បាត់ប៉ក់ក៏អត់ដឹង

ដារ៉ា : អីចឹង ឡេង អាន់ នឹងឡេង ប៉ក់នេះ លោកតាថា ស្លាប់ដោយសារថា អត់ឃើញមកភូមិវិញ តាំងពីបែក ៧៩ មក ។ អីចឹងដោយសារថា តាំងពីបែក៧៩មក អត់ឃើញមកភូមិវិញ លោកតាសន្និដ្ឋានថា ស្លាប់

អឿក : ស្លាប់ បើសិនណាជាទៅបរទេស មានដឹងហើយ

ដារ៉ា : អីចឹង?

អឿក : យល់អីចឹងហើយ, ល្មមដឹងល្មមត្រូ

ដារ៉ា : កាលពីដើមពីអីមោ ក្នុងភូមិលោកតា ស្ថានភាពរស់នៅអីយ៉ាងម៉េចដែរលោកតា?

អឿក : ភូមិពីដើមមោ ភូមិស្ថានភាពអីវា ដូចថាវាមិនជាអីប៉ុន្មាន ល្មម

ដារ៉ា : ជីវភាព

អឿក : ជីវភាពអីវាមិនសូវមានដូចជាថា ខ្វះខាតអីប៉ុន្មានទេ គ្រាន់តែថាវាគ្រប់គ្រាន់ ឬមួយសល់តិចតួច ខ្វះថាឧបមាថា ចំនួន១០០នាក់អី ខ្វះតែប្អូនដប់នាក់ទេ

ដារ៉ា ៖ ចុះមានជាចលនាអីទេលោកតា? ចុះនៅក្នុងភូមិលោកតាពីសង្គមអីចង់និយាយសង្គមរាស្រ្តនិយមមានជាចលនាអីទេ? ចលនាបដិវត្តន៍អីនៅក្នុងភូមិលោកតារស់នៅ?

អឿក ៖ មាន មុនដំបូងមានមែន

ដារ៉ា ៖ ជួយរៀបរាប់ប្រាប់ពួកខ្ញុំបន្តិចមើល?

អឿក ៖ រៀបរាប់ម៉េច បើមិនច្បាស់ដែរហ្នឹង បើមានគេមោចលនាដូចថា ឲ្យកែប្រែយ៉ាងម៉េចៗឲ្យគិតគូររបបសង្គមនិយម ដល់ធ្វើទៅវាលំបាក គ្មានស្រណុកអីទេ ធ្វើទៅ ឧទាហរណ៍ថាធ្វើទៅ១០ វាត្រូវ២ដែរ តែខុសដល់ទៅ៨ណោះ បើតាមខ្ញុំយល់ទេណា ប៉ុនដឹងធ្វើយ៉ាងម៉េច បើខ្ញុំនៅក្រោមគេហើយជិះក៏ប៉ាល់កណ្តាលទន្លេហើយ បើហក់ទៅក៏ស្លាប់ វាអីចឹងណាវាលំបាកវាលំបាកហើយ មិនដូចយើងពីដើមមិនលំបាកអីចឹង មិនដែលលំបានកដល់ថ្នាក់ហ្នឹងទេ លំបាកដល់បែកខ្នែក ឪពុកខ្ញុំនៅដោយឪពុកខ្ញុំ លំបាកខ្លាំងណាស់ មិនមែនស្រណុកទេៗ ដល់មោពេលឥឡូវ វាស្រួលដែរ កាលពីដើមមោក៏វាអត់លំបាកដូចអាហ្នឹងដែរ ដល់សង្គម ពត នេះវីវរធំតែម្តង

ដារ៉ា ៖ ពីដើមមោ អ៊ីរស់នៅភូមិនេះ?

អឿក ៖ ភូមិខ្ញុំនៅទទឹងថ្ងៃ

ដារ៉ា ៖ ភូមិនៅទទឹងថ្ងៃ ភាគច្រើនថានៅភូមិទទឹងថ្ងៃមានរៀបចំជាចលនាកុម្មុយនិស្ត សំដៅទៅលើចលនាខ្មែរក្រហមហ្នឹងណា មានតាំងពីឆ្នាំ៧០អីណោះលោកតា?

អឿក ៖ បាទ

ដារ៉ា ៖ ហើយគេថា មានជាភូមិគំរូភូមិអីលោកតា អាភូមិទទឹងថ្ងៃគេហៅភូមិគំរូលោកតា?

អឿក ៖ អានេះវា ដល់ហើយគេដាក់ភូមិគំរូភូមិអីចឹងទៅណា ភូមិហ្នឹងភូមក្បាលអូ

ដារ៉ា ៖ ភូមិក្បាលអូ ឥឡូវយើងហៅថា ភូមិទទឹងថ្ងៃ?

អឿក ៖ បាទ

ដារ៉ា ៖ ជំនាន់ហ្នឹងមានជាការ ដូចថា ខ្មែរក្រហមមានលាក់គ្រាប់លាក់អី ចាប់ផ្តើមប្រឆាំងនឹងរបបលន់ ណល់អីលោកតា?

អឿក ៖ បាទ ហ្នឹងហើយ

ដារ៉ា ៖ សូមលោកតាជួយរៀបរាប់ឲ្យបានច្បាស់ជាងហ្នឹងបន្តិចបានទេលោកតា ស្ថានភាពដូចថាមានជាចលនាខ្មែរក្រហម មានលាក់គ្រាប់លាក់អី ហើយមានអ្នកស្រុកអ្នកភូមិជួយយ៉ាងម៉េចៗអីលោកតា?

អឿក ៖ ទេអាហ្នឹងមិនច្បាស់ទេ តែចេះតែពូ តែខ្ញុំអត់សូវហ៊ានទៅ ប៉ុនពូគេថាទេណា មានលាក់គ្រាប់លាក់អី មានលោកនេះលោកនោះមោតាមផ្លូវហ្នឹង មានគេលាក់អីចឹងទៅ គ្រាន់តែពូប៉ុនមិនដែលទៅ

ដារ៉ា ៖ ដែលពូមានលោកនេះលោកអីមោជួយលាក់អី ដែលពូជាឈ្មោះអីដែរលោកតាកាលហ្នឹង?

អឿក ៖ ពូដែរ

ដារ៉ា ៖ ឈ្មោះអីលោកតា?

អឿក ៖ យីឈ្មោះហ្នឹង ឈ្មោះនៃ, ជួន ជឿន ឈ្មោះ ខៀវ សំផន តាមពូទេណា មានឈ្មោះពីរនាក់ហ្នឹងចូលមោផ្លូវហ្នឹង

ដារ៉ា ៖ គឺថាមោរបៀបជាលាក់ខ្លួន?

អឿក ៖ លាក់ មោហ្នឹងលាក់ខ្លួន ឲ្យបែកណាបាន

ដារ៉ា៖ ពេលថ្ងៃហ្នឹង?

អឿក ៖ លាក់ខ្លួនហ្នឹងតែម្តង ជួនលាក់នៅស៊ីង

ដារ៉ា ៖ ថ្ងៃលាក់ខ្លួននៅស៊ីង ស៊ីងគេហៅស៊ីងអី?

អឿក ៖ គេហៅស៊ីង មិនដឹងស៊ីងអីទេនេះ

ដារ៉ា ៖ អាហ្នឹងជាព្រំប្រទល់ជាមួយកំពង់ស្ពឺ ស្រុកបសែតអីចឹងលោកតា?

អឿក ៖ បាទ, ស៊ីងជិតដែរ ប្រហែលជាមួយគីឡូ

ដារ៉ា ៖ ហើយដល់ពេលអីចឹងទៅលោកតារស់នៅភូមិហ្នឹងហូរហែររហូតមោអីចឹងទៅ?

អឿក ៖ បាទ

ដារ៉ា ៖ រហូតមកដល់ពេលខ្មែរក្រហមទទួលបានជោគជ័យ?

អឿក ៖ បាទ

ដារ៉ា ៖ ពេលរំដោះឆ្នាំ៧៥

អឿក ៖ បាទ

ដារ៉ា ៖ ពេលរំដោយឆ្នាំ៧៥ លោកតាត្រូវបានគេបញ្ជូនទៅ

អឿក ៖ ខ្ញុំគេបញ្ជូនទៅកៀនស្វាយ

ដារ៉ា ៖ ការបញ្ជូនការអីគេបញ្ជូនយ៉ាងម៉េចលោកតា?

អឿក ៖ ទេ គេផ្លាស់ប្តូរមនុស្សយ៉ាងម៉េច ខ្ញុំមិនដឹង ខ្ញុំពិបាកយល់ ជួនផ្លាស់ពីនោះទៅនោះ ពីស្រុកនោះទៅស្រុកនោះ ខ្ញុំចេះតែឆ្ងល់ ហើយចុះចាំផ្លាស់ធ្វើអី ផ្លាស់ដើម្បីអីចេះទេ កុំឲ្យមានកម្មសិទ្ធិខ្លួន បើតាមខ្ញុំយល់ ប៉ុនបើឯងមិនទៅវាស្លាប់ អត់រើងទទឹងទេ ថាឲ្យទៅគឺទៅហើយ

ដារ៉ា ៖ អ្នកណាចាត់ចែងរឿងការផ្លាស់ប្តូរអីចឹង?

អឿក ៖ ឃុំ ស្រុក

ដារ៉ា ៖ កាលហ្នឹងឃុំស្រុកអ្នកណា?

អឿក ៖ នៅអង្គរកា

ដារ៉ា ៖ ឈ្មោះអីគេ?

អឿក ៖ ស្រុកឈ្មោះគ្រូ........ បើឃុំនៅចាំ

ដារ៉ា ៖ ឈ្មោះអីគេ?

អឿក ៖ មានឈ្មោះ ពេន, ពត អីហ្នឹង ពេន ស្លាប់ហើយ

ដារ៉ា ៖ ពេន ស្លាប់ហើយ? ពត ស្លាប់ដែរ?

អឿក ៖ ពត នៅ

ដារ៉ា ៖ គាត់ហ្នឹងធ្វើឃុំរហូតទល់តែដល់វៀតណាមចូល ឬយ៉ាងម៉េច?

អឿក ៖ ធ្វើរហូត ប៉ុនគេបញ្ជូនដែរ គេបញ្ជូនគាត់ទៅរៀនស្វាយ ទៅអីណា

ដារ៉ា ៖ អីចឹងលោកតារៀបរាប់មើល តើជីវិតលោកតាពេលគេឲ្យទៅរៀនស្វាយគេឲ្យធ្វើអីៗតទៅទៀតទៅ?

អឿក ៖ កាលណោះអ្នកឃុំគេឲ្យធ្វើឃុំ

ដារ៉ា ៖ ចុះលោកតាគេឲ្យធ្វើឃុំដែរ?

អឿក ៖ ខ្ញុំអត់ធ្វើ ខ្ញុំគេឲ្យធ្វើខាងដឹកជញ្ជូន

ដារ៉ា ៖ កងដឹកជញ្ជូន

អឿក ៖ ដឹកជញ្ជូនស្រុក គ្រាន់បានដឹកជញ្ជូនទេ

ដារ៉ា ៖ ដឹកជញ្ជូនអីខ្លះទៅកាលនោះ?

អឿក ៖ ស្រូវ ពោត ដូចថាក្នុងស្រុកអីណា បើគេស្នើទៅ បើស្រូវប្រាំងបញ្ជូនតាមការណ្ឌត បើខែប្រាំងតាមឡាន ធ្វើតែចឹង យើងសម្រាប់មើលខុសត្រូវដាក់ឡាន ដាក់កាណូតអីចឹងទៅ

ដារ៉ា ៖ ជញ្ជូនដឹកទៅខាងណាខាងអីលោកតា?

អឿក ៖ ដឹកដាក់ឲ្យឃុំវិញ

ដារ៉ា ៖ ប្រមូលផលពីតាមគ្រប់កន្លែងទៅ

អឿក ៖ តាមឃុំ របស់ឃុំណាឲ្យឃុំហ្នឹងៗ

ដារ៉ា ៖ ដឹកមោប្រគល់អីចឹងមានបញ្ជីស្នាមអីទេលោកតា?

អឿក ៖ មាន ដូចថាឃុំណាមួយនៅជាងអត ដូចថាមានប៉ុន្មានបាវអីចឹងទៅ ហើយកត់ទៅថ្នាក់លើ គិតតាមបាវ បញ្ជូនទៅថ្នាក់លើ តែឃុំគេធ្វើ ស្រូវប្រាំង តែបើទៅដឹបូងវេទនាណាស់ ខ្ញុំមោជញ្ជូនតែនៅតំបន់ទេ យកទៅចែក ជញ្ជូនហើយចែកឲ្យគេ ចែកតាមអីចឹងទៅ

ដារ៉ា ៖ ចែកតាម

អឿក ៖ ហើយឃុំចែកតាមភូមិៗ យើងទៅដល់ទម្លាក់ឲ្យឃុំ ដូចថា១០០បាវអីចឹងទៅណា ឲ្យគេក្រិបហើយ យើងមោវិញមោៗ ដល់ស្អែកទៅណាឃុំនោះ ដល់ស្អែកទៅណា ឃុំនោះទៀត រាល់ថ្ងៃលីចង់ងាប់

ដារ៉ា ៖ ការដាក់ផែនការទៅឃុំណាៗចេញពីខាងណាវិញ?

អឿក ៖ ចេញពីស្រុក គេដាក់សំបុត្រមោឲ្យហើយ

ដារ៉ា ៖ ស្រុកត្រាំកកយើង?

អឿក ៖ មិនមែនទេ ស្រុកកៀនស្វាយ

ដារ៉ា ៖ កាលពីអឺនៅឃុំនេះ ពេលដែលខ្មែរក្រហមរំដោះបានភ្លាម ឃុំជាងទងមានតា ពត អីចឹង ស្រុកត្រាំកកមានអ្នកណាជាស្រុក?

អឿក ៖ ...នៅព្រាំប្រទល់ឥឡូវហ្នឹង អត់ដែលជួបសោះ

ដារ៉ា ៖ ប្រាប់ឈ្មោះតិចមើល?

អឿក ៖ ព្រោះស្រុកមានពីរបីនាក់ណោះ ឈ្មោះ តា ចំ តា ចុកអី

ដារ៉ា ៖ តា ចុង?

អឿក ៖ តា ចុង ហៅតា ចុងទេ

ដារ៉ា ៖ ហៅតាអី?

អឿក ៖ តាចំ

ដារ៉ា ៖ អ្នកខ្លះហៅតាចំ អ្នកខ្លះហៅតា ចុង

អឿក ៖ បាទ បងគាត់ឈ្មោះ តា ចុក ហើយបងទៀតឈ្មោះ ជឿន តាអាចារ្យ ជឿន ហៅតាម៉ុកហ្នឹង ហើយតាជឿន ឈ្មោះតា ១៥ផង តាមម៉ុកផង តាជឿនឈ្មោះកំណើត តាមពុកគេថា ឈ្មោះ ជឿនទេ ហ្នឹងបានដឹងឈ្មោះបីតែម្តង

ដារ៉ា ៖ ឈ្មោះ តា១៥ដែរ?

អឿក ៖ បាទ ឈ្មោះតា ១៥

ដារ៉ា ៖ អីចឹងស្រុកត្រាំកកនេះ មានប្រធានស្រុកឈ្មោះតា ចុង តាចុក?

អឿក ៖ បាទ

ដារ៉ា ៖ ឈ្មោះពីរមនុស្សតែម្នាក់?

អឿក ៖ ឈ្មោះពីរមនុស្សពីរ មើលណា តាជឿន តាចុង តាចុក ...តាចាយគ្រាន់តែបងប្អូន

ដារ៉ា ៖ តាចាយ ធ្លាប់ជាស្រុកហ្នឹងដែរ?

អឿក ៖ បាទ

ដារ៉ា ៖ ស្រុកត្រាំកកដែរ

អឿក ៖ បាទ

ដារ៉ា ៖ សុទ្ធសែរតាម៉ុកទាំងអស់?

អឿក ៖ ដឹងម៉េចទេ ខ្ញុំវាភ្លេចមិនបាន

ដារ៉ា ៖ ចុះត្រឡប់មកក្រោយវិញ ប្អូនរបស់លោកតាឈ្មោះតា ឡុង អាន់ ពេលខ្មែរក្រហមរំដោះឆ្នាំ៧៥ តា អាន់គាត់ធ្វើអី?

អឿក ៖ កាលណោះនិយាយឲ្យត្រង់ គេឲ្យនៅមន្ទីរក្រាំងតាចាន់

ដារ៉ា ៖ គាត់ធ្វើការនៅមន្ទីរក្រាំងតាចាន់ ហើយលោកតាធ្លាប់បានទៅលេងអីគាត់ដែរ?

អឿក ៖ ខ្ញុំអាចឹងៗខ្ញុំអត់ទៅជិតទេ ពីដើមតែស្រុកខ្ញុំមិនដែលទៅផង ខ្ញុំនៅចាកតែដាល ស្រុកនៅអង្គរកា ខ្ញុំមិនដែលទៅ

ដារ៉ា ៖ គាត់មានដែលមោលេងភូមិលេងអីដែរ?

អឿក ៖ អត់ដែលជួបដែរ ព្រោះអីខ្ញុំនៅនោះ ចាក់ដាលបៀតវត្ត

ដារ៉ា ៖ ចាក់ដាលក្នុងភូមិអីគេលោកតា?

អឿក ៖ ភូមិព្រៃស្បាត ហៅត្រពាំងខ្ទៅ

ដារ៉ា ៖ ភូមិព្រៃស្បាត

អឿក ៖ ភូមិត្រពាំងខ្ទៅ ខាងជើងវត្តព្រៃស្បាត

ដារ៉ា ៖ ភូមិត្រពាំខ្ទៅ នៅក្នុងស្រុកជិតវត្តព្រៃស្បាត?

អឿក ៖ បាទ

ដារ៉ា ៖ នៅក្នុងឃុំអី ជាងទងដែរ?

អឿក : ឃុំដាងទង

ដារ៉ា : ហើយដល់ពេលហ្នឹងទៅ លោកតាក៏បែកពីភូមិទៅកៀនស្វាយ

អឿក : គេបញ្ជូនទៅ

ដារ៉ា : ហើយប្អូនលោកតា តាឡេង អាន់ នេះគាត់នៅក្រាំងតាចាន់

អឿក : បាទ

ដារ៉ា : មន្ទីរស្រុក

អឿក : បាទ

ដារ៉ា : គាត់ជាប្រធានអី

អឿក : អត់ដឹងជាអី ព្រោះពីរបីនាក់ពួកនៅហ្នឹង មួយឈ្មោះ សៀងទៅពីនេះទៅ ប៉ុនមិនដឹងណាជាប្រធានទេ

ដារ៉ា : មានឈ្មោះ សៀង ដែរ ស្អីគេសៀង?

អឿក : ឱ្ក សៀង បើតាមឪ ឪឈ្មោះឱ្ក ហើយតាមជីតាវិញ អែម សៀងអីចឹងតែម្តង

ដារ៉ា : អែម សៀង កាលហ្នឹងធ្វើការជាមួយប្អូនលោកតាឈ្មោះ ឡេង អាន់?

អឿក : បាទ ហើយមួយទៀតខ្ញុំអត់ស្គាល់ គេធ្វើពីរបីនាក់ណោះ មិនដឹងអ្នកណាខ្លះ ខ្ញុំមិនដែលទៅជិតទេ

ដារ៉ា : នៅក្នុងស្រុកភូមិនេះភាគច្រើនត្រកូលគេយកជីតា ឬត្រកូលជីតា?

អឿក : ជីតា

ដារ៉ា : អត់យកឪពុកទេអីចឹង?

អឿក : ខ្លះគេយកឪពុក

ដារ៉ា : ដូចលោកតាយកអី?

អឿក : ខ្ញុំយកជីតាដែរ ឡេងហ្នឹងជីតា

ដារ៉ា : ឡេងហ្នឹងជីតាជាឈ្មោះ ឬជាត្រកូល

អឿក : ត្រកូលខ្ញុំ ដៃ ភឿក ហើយដល់ដើមមោ ឡេង អឿក ខ្ញុំដាក់ទាំងពីរអីចឹងតែម្តង

ដារ៉ា : ចុះរាល់ថ្ងៃលោកតាដាក់ត្រកូលអី?

អឿក : ដៃ អឿក

ដារ៉ា : ដៃ អឿក?

អឿក : បាទ

ដារ៉ា ៖ ផៃ ជាឪពុក

អឿក ៖ បាទ

ដារ៉ា ៖ ហើយត្រកូលរបស់ឪពុកឈ្មោះឡេង

អឿក ៖ បាទ

ដារ៉ា ៖ ហើយឡេងនេះជាឈ្មោះរបស់ជីតា

អឿក ៖ បាទឈ្មោះរបស់ជីតា

ដារ៉ា ៖ អ៊ីចឹងប្អូនប្រុសរបស់លោកតា ឡេង អាន់ ធ្វើការនៅក្រាំងតាចាន់

អឿក ៖ បាទ

ដារ៉ា ៖ តែកាន់តំណែងអីៗលោកតាអត់ដឹង

អឿក ៖ អត់ដឹង

ដារ៉ា ៖ ក្រោយមកមានអ្នកស្រុកអ្នកភូមិប្រាប់លោកតាថាគាត់ធ្វើអីនៅក្រាំងតាចាន់ តាដឹងទេ?

អឿក ៖ អត់ដឹងទេ មិនដឹងអាម៉េច

ដារ៉ា ៖ កាលរស់ក្នុងភូមិ កាលរស់នៅជំនាន់តស៊ូអី ប្អូនលោកតានៅក្នុងភូមិជាមួយលោកតាដែរ?

អឿក ៖ អត់ទេ វានៅភ្នំពេញ

ដារ៉ា ៖ នៅភ្នំពេញវិញ នៅភ្នំពេញធ្វើអីលោកតា?

អឿក ៖ ខាងសារព័ត៌មាន កាសែត ពីដំបូង

ដារ៉ា ៖ អ៊ីចឹង?

អឿក ៖ បាទ

ដារ៉ា ៖ គាត់ធ្វើជាសារព័ត៌មាន ខាងកាសែតអីវិញនៅភ្នំពេញ?

អឿក ៖ បាទ

ដារ៉ា ៖ តា ឡេង អាន់ ហ្នឹង?

អឿក ៖ បាទ

ដារ៉ា ៖ ហើយគាត់មានបានបួសរៀនសូត្រអីទេ?

អឿក ៖ អត់ទេ ដូចថារៀនសាលាបារាំង ហ្នឹងវាមានចេះខ្វះ

ដារ៉ា ៖ នៅភូមិយើងហ្នឹងមានដែរ មានសាលាបារាំងដែរ?

អឿក ៖ វារៀនតាំងពីនៅសាលានៅតូចតាចមោ នៅសាលាដូចថាមើលរួច ទៅអគ្គរកាមាន ...ដល់សែទីវិកាអ៊ីចឹងទៅ

ដារ៉ា ៖ ប្អូនលោកតាឈ្មោះ ឡេង អាន់ រៀនបានថ្នាក់ណាដែរ?

អឿក ៖ មិនដឹងដែរ ប៉ុនចេះក្រែល រៀនដល់ថ្នាក់ណាខ្ញុំអត់ដឹង

ដារ៉ា ៖ គ្រាន់តែដឹងចេះក្រែល

អឿក ៖ បាទ ចេះអាចនិយាយអីកើត

ដារ៉ា ៖ អីចឹងទៅភ្នំពេញទៅធ្វើកាសែតនៅឆ្នាំណាលោកតា?

អឿក ៖ បែបខ្ទង់ឆ្នាំ៥៥-៥៦អីណោះ តាមមើលទៅ ព្រោះកាលនោះយូរដែរហើយ

ដារ៉ា ៖ ធ្វើសារព័ត៌មាន ធ្វើកាសែតពេលហ្នឹង ហេតុអីធ្វើសារព័ត៌មាន ធ្វើកាសែតធ្លាប់ចេញចូលភូមិញឹកញាប់ទេ?

អឿក ៖ អត់ដែលមោនេះ បែបគេចាត់ទៅណាទៅវិញ យកសារព័ត៌មានអីចេះចោះនោះណា បែបរបៀបអីចឹង

ដារ៉ា ៖ នៅភ្នំពេញវិញ ហើយគេចាត់ទៅផ្សេង អត់មោភូមិស្រុកយើងហ្នឹងទេ

អឿក ៖ អត់ទេ

ដារ៉ា ៖ អត់មោអីចឹង ចុះហេតុអីបានពេលខ្មែរក្រហមរំដោះមោ គាត់បានមោធ្វើការនៅក្រាំងតាចាន់វិញលោកតា?

អឿក ៖ ខ្ញុំមិនដឹងច្បាស់ បើតាមខ្ញុំយល់វាមានអាដែងមេនៅភ្នំពេញ មោៗតាមមិត្ត តាមរបៀបយើងយល់ទេណា ប៉ុនមិនដឹងអីចឹង ឬមួយក៏មិនអីចឹង នេះបើតាមខ្ញុំយល់ខ្លួនខ្ញុំ បើអត់ម៉េចទៅកើត

ដារ៉ា ៖ តែពូថា តាឡេង អាន់គាត់ធ្លាប់ពួកទាហានលន់ ណល់អីចាប់ដែរ

អឿក ៖ ចាប់, ចាប់ម្ដង

ដារ៉ា ៖ ពូថាចាប់អី

អឿក ៖ ដាក់អន្ទ្ករកា

ដារ៉ា ៖ ដាក់អន្ទ្ករកា កន្លែងទាហាន

អឿក ៖ ចាប់ដាក់គុកងងឹត ហើយខ្ញុំមិនបានឃើញ ខ្ញុំអត់ហ៊ានទៅ ខ្លាចគេ

ដារ៉ា ៖ ពេលគេចាប់ហ្នឹង លោកតាដឹងដែរ?

អឿក ៖ ដឹង ប៉ុនអត់ហ៊ានទៅ, ដឹងតើ

ដារ៉ា ៖ ចាប់ដោយមូលហេតុអី?

អឿក : មិនដឹង ខ្ញុំឆ្ងល់ វាយកសំណាញ់ទៅបង់ ស្ដាប់សូរទៅ ប៉ូលិសគេទៅពីរបីនាក់ហៅចាប់យកទៅ ហើយខ្ញុំក៏មិនដែលទៅជិតទៅទៀត ចាំមើលវាទៅយ៉ាងម៉េចទៅវិញ ព្រោះខ្ញុំមនុស្សខ្លាច ខ្លាចច្រើនណាស់ គុកក៏មិនដែលជាប់ ព្រោះខ្ញុំវាអាងអីចេះ ខ្ញុំអាងមានច្បាប់ តែធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ បើអ្នកឯងធ្វើអាក្រក់ គឺផលអាក្រក់វាហុចឲ្យខ្ញុំយល់អីចឹង ខ្ញុំតាម ធម៌ព្រះ ខ្ញុំលេងអីចឹង អត់ចេះជាប់គុកជាប់អីទេខ្ញុំ អាណាខ្លះគេយកទៅដាក់ មោវិញគេបញ្ជូនទៅណាៗខ្ញុំរួចខ្លួន គេថាតាឯងបានចិត្តល្អ បើទុកនេះខ្ញុំអត់ឲ្យទៅដែរ គេអ្នកស្គាល់ គេស្គាល់ខ្ញុំ គេនៅធ្វើឃុំថា កុំភ័យ ខ្ញុំធ្លាប់ដោះស្រាយតែអីចឹង

ដារ៉ា : អ្នកនៅឃុំឈ្មោះអី?

អឿក : ពត, ឈួន ស្លាប់ហើយនៅភ្នំពេញ សិតហ្នឹងក៏ស្លាប់ដែរ ឥឡូវហ្នឹងនៃ ជា តា ជា

ដារ៉ា : ឡេង អាន់ ជាប់គុកប្រហែលជាប៉ុន្មានឆ្នាំដែរលោកតា?

អឿក : កាលហ្នឹងមិនដឹងហាប៉ុន្មាន ខ្ញុំអត់ចាំ គេយកទៅតាមត្រុ គេចងខ្សែពួរគេទាញខ្មោកដល់លើគេទម្លាក់មោវិញ ដល់អីចឹងខ្ញុំខ្លាចខ្ញុំអត់ហ៊ានទៅ ធ្វើបាបខ្លាំង

ដារ៉ា : តា អាន់ លន់ ណល់ធ្វើបាបខ្លាំង?

អឿក : បាទ

ដារ៉ា : ជាប់នៅកន្លែងលន់ ណល់ប៉ុន្មានឆ្នាំ ប៉ុន្មានខែអីទៅ?

អឿក : យូរដែរហ្នឹង មិនដឹងប៉ុន្មាន ខ្ញុំអត់ចាំដែរទេ ជាប់ខ្ទង់ពីរបីឆ្នាំឯណោះ គេធ្វើគុករៀបថ្មងងឹតឈឹង ដល់ស្រុកអីចឹងខ្ញុំអត់ដែលទៅផ្សារអីទេ ព្រោះអត់ត្រូវការអី ហើយផ្សារគ្មានលក់អីផង ខ្ញុំរត់រកកន្លែងសុខ ទៅចាក់ផលទៅ

ដារ៉ា : ចុះពេលដែល ធ្វើម៉េចឡេង អាន់ រួចផុតពីគុក?

អឿក : អត់ដឹង មិនដឹងជាវារត់អីក៏មិនដឹង ខ្ញុំអត់ដឹងទេកាលហ្នឹង

ដារ៉ា : ពេលរួចពីគុកមោ គាត់មោផ្ទះមោសម្បែងដែរ?

អឿក : បែបដូចអត់មោទេ ផ្ទះវានៅនោះ ប្រពន្ធវាក៏បងប្អូនដែរ ជីដូន១

ដារ៉ា : ប្រពន្ធគាត់ឈ្មោះអី?

អឿក : ឈ្មោះ សារុន

ដារ៉ា : សារុន?

អឿក : បាទ

ដារ៉ា ៖ អីសារុនលោកតា?

អឿក ៖ សាំង សារុន

ដារ៉ា ៖ សាំង សារុន

អឿក ៖ បាទ

ដារ៉ា ៖ រាល់ថ្ងៃប្រពន្ធគាត់នៅរស់ទេ

អឿក ៖ នៅ កូនក៏មាននៅ

ដារ៉ា ៖ កូនក៏មាននៅដែរ

អឿក ៖ ហ្នឹងត្រូវប្អូនថ្លៃខ្ញុំ

ដារ៉ា ៖ ជួបមកតាមដូវដែរគឺថា យាយសាំង សារុនគាត់នៅមេម៉ាយ

អឿក ៖ បាទ

ដារ៉ា ៖ មេម៉ាយតាំងពីបែក

អឿក ៖ តាំងពីបែកអាពត គិតទៅ៣០ឆ្នាំជាងហើយ

ដារ៉ា ៖ អីចឹងគាត់អត់ដែលនឹកនារកគ្រួសារអីទេ?

អឿក ៖ គាត់រកបងប្អូនគាត់ទៅ អត់មានឃើញ អត់ជួប បងប្អូនមាននៅព្រាំប្រទល់ដែរ

ដារ៉ា ៖ ឮថាគាត់មានកូន កូនយាយសារុននៅ

អឿក ៖ បាទមាន

ដារ៉ា ៖ ខ្ញុំចង់បញ្ជាក់បន្តិចដែរលោកតា ព្រោះនៅនេះមានលោកតាស្គាល់ទេ កូនគាត់ឈ្មោះ ឡេង ភ័ណ កូនយាយសារុន?

អឿក ៖ កូនស្រី?

ដារ៉ា ៖ បាទ កូនស្រីយាយ សារុន

អឿក ៖ មានកាភូ កាភ័ណ នៅលិចហ្នឹង

ដារ៉ា ៖ ចុះតា សាំង យាយ មុំ ត្រូវជាយ៉ាងម៉េចជាមួយលោកតា?

អឿក ៖ ត្រូវ មីង មា

ដារ៉ា ៖ ត្រូវមីង មា

អឿក ៖ បាទ

ដារ៉ា ៖ តា សាំង យាយ មុំត្រូវ

អឿក ៖ ត្រូវមីង មុំ មីងបង្កើត តា សាំងអ្នកដទៃ ពីដើមមោធ្វើពូខ្ញុំមោដណ្ដឹងមីង

ដានី ៖ ត្រូវឪពុកម្ដាយរបស់ សារុន

អឿក ៖ បាទ

ដារ៉ា ៖ បងស្រី ភ័ណ ម្ដាយកូនយាយរុន

អឿក ៖ បាទ

ដារ៉ា ៖ ឪពុកគាត់ឈ្មោះ ឡេង អុន ម៉េចដែរលោកតា?

អឿក ៖ ឡេង អុន! ឡេង អុនណា មានតែក្មួយខ្ញុំនៅនេះ

ដារ៉ា ៖ អុន

អឿក ៖ នៅនេះ

ដារ៉ា ៖ អីចឹងគាត់ឡេង អុន ម្ដាយគាត់ឈ្មោះ សារុន ហើយតាមលោកតាថា យាយរុន គាត់គ្រួសាររបស់ តា អាន់, ឡេង អាន់, អីចឹងមានគាត់ភរខ្ញុំ, អីចឹងមានតែឈ្មោះ ភ័ណ ហ្នឹងភរខ្ញុំ ថាឪពុកឈ្មោះឡេង អុន ឬក៏លោកតាអត់ដឹងថា តា អាន់ គាត់ដូរឈ្មោះទៅជា ឡេង អុនដែរ?

អឿក ៖ អត់ដឹង

ដារ៉ា ៖ វាអាចអីចឹងដែរលោកតា

អឿក ៖ បាទ

ដារ៉ា ៖ តែពីមុនមោ លោកតាអត់មានដឹងថា ឡេង អាន់ មានដូរឈ្មោះអី

អឿក ៖ អត់ដឹង

ដារ៉ា ៖ កាលនៅក្រាំងតាចាន់ ឡេង អាន់ នៅតែឈ្មោះឡេង អាន់អីចឹង?

អឿក ៖ មិនដឹងអាម៉េច មិនដឹងគេផ្លាស់ឈ្មោះមិនដឹង ខ្ញុំអត់ដឹងដែរ (.....សំឡេងអ្នកជិតខាង)

ដារ៉ា ៖ ប្រែទៅជាឈ្មោះអីលោកតា

អឿក ៖ អត់ដឹង

ដានី ៖ ពេលលោកតាទៅខាងកៀនស្វាយ ដឹកជញ្ជូនហ្នឹងនៅដល់ពេលណាទៅ?

អឿក ៖ ទៅនៅហ្នឹងដល់បែក ខ្ញុំរត់ ដើរមកវិញមោ គេអត់ឲ្យមោអ្នកស្រុក ដូចថាស្រឡាញ់ដប់ ស្អប់មួយមិនដឹង ក្រែងលោឯងឲ្យគេមិនគ្រប់មិនគ្រាន់អី មិនគ្រប់មែន ចុះបើរបស់តិច ឲ្យម៉េចគ្រប់ ម្ល៉ោះហើយវា អើធ្វើវាមានខុសមានត្រូវ មានខុសទាំងអស់ ក៏មានត្រូវទាំងអស់ទេ ។

ដារ៉ា ៖ ចុះគណៈស្រុកកៀនស្វាយឈ្មោះអីទៅ?

អឿក ៖ ឈ្មោះ យាយ បូ មួយ ឈ្មោះ តា ហាក់ ពីរ ឈ្មោះ ហឿន បី ហឿនខ្វះភ្នែកម្ខាង ប៉ុនមិនដឹងនៅស្រុកណាទេ

ដានី ៖ យាយ បូ

អឿក ៖ យាយ បូ នៅស្រុកនេះ ក្បាលអូ

ដានី ៖ ក្បាលអូ ទទឹងថ្ងៃ?

អឿក ៖ បាទ

ដានី ៖ គាត់ស្គាល់លោកតាដែរ?

អឿក ៖ ថឺមិនស្គាល់ គេហៅខ្ញុំទៅធ្វើសេដ្ឋកិច្ចដឹកហ្នឹង

ដានី ៖ ដល់អីចឹងគេហៅលោកតាឲ្យទៅធ្វើសេដ្ឋកិច្ចស្រុកកៀនស្វាយហ្នឹង

អឿក ៖ បាទ មិនប្រធានមានគេប្រធានមួយទៀត ប្រធានមួយនៅតាកែវ

ដានី ៖ លោកតានៅភូមិក្បាលអូ អ្នកដែលបានចេញទៅធ្វើធំៗច្រើនដែរ?

អឿក ៖ វាច្រើនដែរកាលហ្នឹង

ដានី ៖ លោកតាចាំដែរ ពីណាទៅ? យាយ បូ មួយ, យាយ បឿនដែរ យាយបឿន គាត់ធ្វើអី?

អឿក ៖ ឃុំជាងទង

ដានី ៖ បានធ្វើគណៈស្រុកអីដែរ

អឿក ៖ កាលនោះបានធ្វើអីមិនបាន ខ្ញុំអត់នៅដែរ ខ្ញុំទៅនោះទៅ

ដានី ៖ ចុះអ្នកផ្សេងទៀត?

អឿក ៖ អ្នកផ្សេងទៀត ខ្ញុំមិនសូវដឹងដែរ

ដានី ៖ ដូចយាយ ចែម?

អឿក ៖ យាយ ចែម បានគណៈស្រុក

ដានី ៖ យាយ ចែម គាត់ចេញពីក្បាលអូដែរ?

អឿក ៖ បាទ

ដានី ៖ គាត់ធ្វើគណៈស្រុកណាដែរ យាយ ចែម?

អឿក ៖ គណៈស្រុក ទៅពីស្រុកត្រាំកក ស្រុកអី?

ដានី ៖ ស្រុកអង្គរជ័យ

អឿក ៖ អើ ស្រុកអង្គរជ័យហ្នឹងហើយ នៅអង្គរជ័យ ហ្នឹងខ្ញុំធ្លាក់ទាក់ទីនេះទីនោះអីណា

ដានី ៖ ចេញពីអន្លុងវែងគាត់ទៅណាទៀត?

អឿក ៖ ទេ ខ្ញុំទៅនោះទៅ មិនដឹងគាត់ទៅណា ខ្ញុំអត់ដឹង ទៅដល់នោះហើយលែងដឹង ប៉ុនដឹងនៅអន្លុងវែងដឹងច្បាស់ កាលខ្ញុំនៅសេដ្ឋកិច្ច ខ្ញុំមោអន្លុងវែង គេសរសេរសំបុត្រឲ្យមោ ឲ្យមកយកកូនជ្រូក មោដល់ជួប ចែម ពេលហ្នឹងតែម្តង ...ឲ្យមកយកកូនជ្រូក ដឹកម៉ាឡាន លែងតែម្តងកូនជ្រូក អាឡានដឹកដី ប្រហែលជិត១០០កូនជ្រូក

ដានី ៖ ជួបយាយ ចែម យាយ ចែមថាម៉េច?

អឿក ៖ មានថាអីបើសំបុត្រមកពីស្រុកគេថាមុនហើយ ខ្ញុំគ្រាន់មកដឹកជញ្ជូន ខ្ញុំមោហុចសំបុត្រឲ្យគេទៅ គេថាអូស្រុកត្បៀនស្វាយសុំកូណជ្រូកប៉ុណ្ណេះ ហើយពីថ្ងៃមុនដឹងហើយ ហើយសន្យាថ្ងៃទៀតឲ្យប្រមូលជ្រូកហើយ ទៅដល់យកកន្ធែងហ្នឹងតែម្តង

ដានី ៖ ចុះលោកតា ប្អូនលោកតាមួយទៀតឈ្មោះ ប៉ក់ គាត់ធ្វើអីដែរ?

អឿក ៖ ធ្វើឃុំ

ដានី ៖ ធ្វើឃុំនៅឯណា?

អឿក ៖ នៅត្បៀនស្វាយដែរ

ដានី ៖ គាត់ធ្វើឃុំរហូតដល់បែក ៧៩ ឬគាត់ធ្វើគណៈស្រុកអីដែរ?

អឿក ៖ ដូចអត់ទេ

ដានី ៖ ចុះឈ្មោះ ប៉ក់ ដែរថាគាត់ទៅធ្វើគណៈស្រុកកោះធំនោះ តាស្គាល់ទេ?

អឿក ៖ ទេ កាលនោះឮគេថា ផ្លាស់ទៅហ្នឹងដែរ ខ្ញុំអត់ដឹង ផ្លាស់ហើយស្រុកកាន់តែយ៉ាប់ទៅៗ គេមិនត្រឹមប៉ុណ្ណឹងទេ គេបញ្ជូនក្រចេះ ស្ទឹងត្រែងអីណាទៀតនោះ

ដានី ៖ អូ បញ្ជូនពូ ប៉ក់?

អឿក ៖ បាទ ខ្ញុំគ្រាន់តែឮ ប៉ុនមិនដឹងធ្វើម៉េច វាស្រុកអីចឹង យើងមិនអាចដើរបាន

ដានី ៖ ប៉ក់កាលនៅត្បៀនស្វាយ ធ្វើឃុំណា?

អឿក ៖ ឃុំក្បាលកោះ ក្បាលកោះស្គាល់ដែរ?

ដានី ៖ អត់ផង, បងណាក់ស្គាល់

អឿក ៖ ស្គាល់ដែរ?

ណាក់ ៖ បាទ ខ្ញុំនៅខាងត្បៀនស្វាយដែរតើ ខ្ញុំនៅកោះប្រាក់

អឿក ៖ កាលខ្ញុំនៅ បែបនៅកុមារទេមើលទៅអី

ណាក់ ៖ នៅកុមារ

អឿក ៖ ហើយដែលពុកឈ្មោះខ្ញុំដែរចុះ?

ណាក់ ៖ អត់ផង, អត់ធ្លាប់ពុផង ។ ខ្ញុំស្គាល់ប្រធានសហករណ៍ កាលនោះឈ្មោះ តា នុយ

អឿក ៖ អត់សូវស្គាល់ទេ ប្រធានសហករណ៍ កាលណោះវាច្រើនពេក បើភូមិឃុំខ្ញុំច្រើនស្គាល់ ពីដើមម៉ាឃុំៗខ្ញុំដឹកនាំ ក្បាលកោះ ភូមិធំ ឃុំលើកដែក ឃុំគគី គគីធំ អស់ត្រឹមគគីធំ ដល់ព្រែកអ្នកលឿង អាហ្នឹងសម្រាប់ខ្ញុំដឹក ម៉ាជួរមាត់ទន្លេបាសាក់ អាណឹងខ្ញុំដឹងកំពុងស្វាយ ស្វាយប្រទាល ត្រើយស្លា អាណឹងគេផ្ទាស់ខ្ញុំមោនៅមាត់ទន្លេមោ គេឲ្យខាងដឹកខ្សាច់ដឹកអីវិញហើយ ដឹកថ្ម

ដានី ៖ ចុះឈ្មោះ វាំង?

អឿក ៖ វាំង នៅក្បាលអូដែរ

ដានី ៖ គាត់ធ្វើអីដែរ?

អឿក ៖ អីបែបធ្វើដល់ស្រុកមើលទៅ វាំង

ដានី ៖ គាត់ស្រុកនៅណាទៅ?

អឿក ៖ ស្រុកកោះអណ្តែត ខ្ញុំមិនបានជួបទៀត

ដានី ៖ ចុះមានអ្នកផ្សេង ដែលគាត់ធ្វើធំៗ?

អឿក ៖ ហ៊ឺ ខ្ញុំអត់ស្គាល់គេទេ មិនដឹងអ្នកណាទេ

ដានី ៖ ចុះកាលណឹង មានគណៈតំបន់ គណៈភូមិភាគមានដែលចុះមកជួប មោស្រុកលោកតាខាងកៀនស្វាយអីដែរ?

អឿក ៖ មាន ប៉ុនគ្រាន់ពុៗ ប៉ុនខ្ញុំមិនដែលបានទៅប្រជុំអីគេអត់ហៅ រវល់អារឿងដឹកជញ្ជូនណឹង

ដានី ៖ កៀនស្វាយកាលណឹងនៅតំបន់ណា តំបន់២៥?

អឿក ៖ បាទ, តំបន់២៥

ដានី ៖ តំបន់២៥ ពីណាគេគណៈតំបន់កាលណឹង?

អឿក ៖ គណៈតំបន់ តាទិត មុនតា ទិត ឈ្មោះភ្លេចឈ្មោះហើយ

ដានី ៖ តា ទិត គាត់នៅរស់ទេ?

អឿក ៖ អត់ដែលជួបដងខ្ញុំ ប៉ុនពុដូចថា ស្លាប់

ដានី ៖ តា ទិត នៅត្រពាំងអំ?

អឿក ៖ បាទ

ដានី ៖ ចុះតាម៉ុកអីធ្លាប់ចុះទៅខាងណុងដែរ?

អឿក ៖ ទៅ, យូរៗទៅម្ដង

ដានី ៖ ស្គាល់លោកតាច្បាស់ទេ?

អឿក ៖ ស្គាល់អីចឹងដែរ ខ្ញុំស្គាល់គាត់វាយូរដែរហើយ ស្គាល់ខ្ញុំនៅបួសណោះនៅត្រពាំងធំអី

ដានី ៖ តាធ្លាប់បួសបានប៉ុន្មានឆ្នាំដែរ?

អឿក ៖ បាន ៨

ដានី ៖ បួស ៨ឆ្នាំ ពីឆ្នាំណាដល់ឆ្នាំណា?

អឿក ៖ អត់ចាំទេ មុនហាសិប បួសហើយបានចូលហាសិប

ដានី ៖ បួសនៅវត្តណា?

អឿក ៖ វត្តមឿងចារ

ដានី ៖ ចុះកាលបួសនៅវត្តមឿងចារ តា ម៉ុកគាត់បួសនៅវត្តត្រពាំងអំ?

អឿក ៖ តា ម៉ុក គាត់ធ្វើការ កាលពីដើមគាត់ធ្វើការនៅភ្នំពេញ

ដានី ៖ ចុះដូចតា នៅ តា ទិត អីគាត់បួសនៅវត្តណាដែរ?

អឿក ៖ ត្រពាំងធំ

ដានី ៖ កាលណុងតាស្គាល់គាត់ដែរ?

អឿក ៖ ស្គាល់ ស្គាល់តា នៅ តា ទិត អត់សូវស្គាល់ទេ

ដានី ៖ អត់ដែលជួបគាត់កាលបួស តា ទិត

អឿក ៖ តា ទិត អត់ទេ, ទេជួបប៉ុនដល់គេអត់ដែរសូវមាត់អី តា នៅជួប តា ទិតអីដែរហ្នឹងទៅ លេងវត្ត ដែលបួសទៅវត្តណឹងមួយវស្សា

ដានី ៖ ទៅនៅវត្តត្រពាំងធំ

អឿក ៖ បាទ

ដានី ៖ កាលណុងតា ទិត គាត់ចេញពីវត្តទៅ?

អឿក ៖ នៅបួស

ដានី ៖ នៅវត្តណឹងដែរ?

អឿក ៖ បាទ

ដានី ៖ ឈ្មោះអី?

អឿក ៖ ដឹងអី ទិត ខ្ញុំមិនសូវ ហើយតានៅ គាត់រៀនបានច្រើន រៀនបានដល់សាកលវិទ្យាសពម្រិតនៅមុខវាំង មែនត្រឹមឌីជ្ជមបួនឆ្នាំទេណា ឡើងពីណឹងទៅដូច៣ឆ្នាំទៀត ឡើង៧ តានៅ

រៀនចេះច្រើនណាស់ កាលមុនជួប មោបុណ្យនេះ ខ្ញុំមើលអត់ស្គាល់ ព្រោះគាត់ចាស់បងខ្ញុំទៅទៀត គាត់បងខ្ញុំពីរបីឆ្នាំ

ដានី ៖ ចុះ តា ទិត ក្រោយគាត់មកវត្ត មានដែលជួបគាត់ទេ?

អឿក ៖ អត់

ដានី ៖ អត់ដែលជួបទេ?

អឿក ៖ ខ្ញុំទៅលិចក៏អត់ដែលជួប ខ្ញុំទៅអង្គៀសលុយធ្វើវិហារ

ដានី ៖ ផ្ទះគាត់នៅណា តា ទិត?

អឿក ៖ ផ្ទះនៅត្រពាំងធំដែរ តែនៅត្រង់ណាខ្ញុំអត់ដឹងទេ

ដានី ៖ ផ្ទះគាត់ឥឡូវ?

អឿក ៖ នៅលិច ប៉ុនដឹងនៅត្រង់ណាទៀត ប៉ុនដឹងថានៅៗ ប៉ុនមិនដឹងនៅត្រង់ណា សួរអាចារ្យនៅ ថានៅ

ដានី ៖ តាបួសពីអាយុប៉ុន្មានដល់អាយុប៉ុន្មានបានសឹក?

អឿក ៖ អាយុ១៥ ប៉ុនបួសហើយចូលដល់អាយុ១៦ឆ្នាំ បួសណេន ៤ បួសភិក ៤

ដានី ៖ ដល់អាយុប៉ុន្មានបានសឹកវិញ?

អឿក ៖ ២៤

ដានី ៖ លោកតារៀបការឆ្នាំណា?

អឿក ៖ សឹកមោបាន៣ឆ្នាំ ការ អាឡៃធ្វើផ្ទះ ធ្វើផ្ទះប៉ុនណឹង ករផ្ទះណឹង ធ្វើខ្លួនឯងតែម្តង

ដានី ៖ ធ្វើផ្ទះហើយបានការ អាម៉េចបានធ្វើផ្ទះហើយបានការ?

អឿក ៖ កាលណុងប្រពន្ធវាកំព្រើកំព្រា នៅជាមួយបងថ្លៃ គេបង្គាប់ថាធ្វើផ្ទះ ធ្វើប៉ុន្មានក៏ដោយ ខ្ញុំនឹកថាបើធ្វើទៅគ្មានគេយក យើងយកដដែល អីចឹងធ្វើទៅ ធ្វើប៉ុនខ្ទមអ្នកតាក៏ឲ្យដែរ ថាហេធ្វើប៉ុនខ្ទមអ្នកតាម៉េច មនុស្សដេក ...ខ្ញុំធ្វើសរសរប៉ុនៗណឹង ...

ដានី ៖ ឆ្នាំណាលោកតា?

អឿក ៖ ហេឆ្នាំហុកប៉ុន្មានទេ

ដានី ៖ លោកតាអាយុប៉ុន្មាន?

អឿក ៖ ២៨, ២៨ ការ

ដានី ៖ ចុះលោកយាយអាយុប៉ុន្មាន?

អឿក ៖ ៣៥

ដានី : លោកយាយអាយុច្រើនជាង លោកតាអាយុ២៨ លោកយាយអាយុ៣៥?

អឿក : បាទ

ដានី : លោកយាយឈ្មោះអីដែរ?

អឿក : ឈ្មោះយាយ ហ៊ឹន

ដានី : អី ហ៊ឹន?

អឿក : វៀម ហ៊ឹន

ដានី : វៀម ហ៊ឹន ហៅក្រៅ ទ្រូល

អឿក : ទ្រូល ផាវ គាត់ធាត់, គាត់ធាត់ទ្រូលៗ

ដានី : លោកតា មានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

អឿក : ២

ដានី : កូនតែ២នាក់ទេ?

អឿក : បាទ

ដានី : មានស្រីមានប្រុស?

អឿក : ប្រុស១ ស្រី១

ដារ៉ា : កូនលោកតាកើតសម័យ៣ឆ្នាំឬកើតក្រោយទេ?

អឿក : អាកូននៅភ្នំពេញកើតសម័យណឹងដែរ តែវានៅតូច

ដារ៉ា : កើតឆ្នាំណា?

អឿក : ដល់បែកវាអាយុប្រហែល២ឆ្នាំហើយ

ដារ៉ា : អីចឹងប្រហែលក្នុង ៧៧

អឿក : បាទ ក្នុង៧៧

ដានី : កូនស្រី?

អឿក : កើតមុនណឹង ប៉ុនវាឈឺ មិនបានទៅណាមោណានៅផ្ទះ

ដារ៉ា : កើតមុនណឹងទៀត?

អឿក : មិនមុនទេ ក្នុងសង្គ្រាមណឹងដែរ

ដានី : អីចឹងលោកតាការហើយយូរបានមានកូន?

អឿក : បាទ, កូនខ្ញុំ៧ឆ្នាំទើបបានមួយ ព្រោះថាដូចខ្ញុំវាខ្ជិលផងអារឿងចឹងៗ....

ដារ៉ា ៖ ចុះលោកតា ឡេង អាន់ប្អូនលោកតារាងរូវដូចលោកតាដែរ ឬយ៉ាងម៉េចជួយរៀបរាប់បន្តិចមើល?

អឿក ៖ វាខុសគ្នាដែរ

ដារ៉ា ៖ មាឌធំជាងលោកតា

អឿក ៖ ធំជាង

ដារ៉ា ៖ សម្បុរម៉េចដែរ?

អឿក ៖ សម្បុរសជាងខ្ញុំតិចដែរ បងប្អូនខ្ញុំ១១នាក់ ខ្មៅជាងគេ២ ព្រោះវាមានពូជអឺចឹងតែម្តង

ដារ៉ា ៖ ខ្មៅ២អ្នកណាខ្លះ?

អឿក ៖ ប្អូនខ្ញុំនៅនេះ ឈ្មោះ ខ្ញុំៗនៅនេះផ្ទះពីរខ្នងក្បែរផ្លូវ ក្រៅពីហ្នឹងស ជាប់សែរចិន

ដារ៉ា ៖ តា ឡេង អាន់ សដែរ?

អឿក ៖ ស ជាងខ្ញុំ

ដារ៉ា ៖ កំពស់កំពរម៉េចដែរ?

អឿក ៖ កំពស់ប្រហែលជា១ម៉ែត្រ៦៥

ដារ៉ា ៖ ខ្ពស់ជាងលោកតា?

អឿក ៖ ខ្ពស់ជាង

ដារ៉ា ៖ អឺចឹង មានតែប្អូនខ្ពស់ជាងបង, ហើយសក់គាត់ម៉េចដែរ?

អឿក ៖ សក់ស្កូត

ដារ៉ា ៖ ហើយមាឌ គាត់រាងក្រអាញ

អឿក ៖ រាងក្រអាញ

ដានី ៖ សំដីសំដៅគាត់យ៉ាងម៉េច?

អឿក ៖ សំដីដំដៅប្រហែលៗខ្ញុំ វាមិនជាគ្នាប៉ុន្មានទេ ហើយរកជួបឃើញដែរ បានសួរអឺចឹង?

ដារ៉ា ៖ ខ្ញុំឆ្ងល់ដែរ ដល់ពេលសួរពីចុងភូមិដល់ដើមភូមិពូតែថា ស្លាប់ ឬបាត់ខ្លួនអឺចឹងលោកតា ហើយអឺចឹងទៅខ្ញុំមិនថាមានកំពស់កំពរ មានរាងរូវអីយ៉ាងម៉េច អត់ដឹងណាលោកតា

ណាក់ ៖ មានសល់រូបថតគាត់ទេលោកតា?

អឿក ៖ អត់ទេ

ដារ៉ា ៖ ពីដើមមកអត់ដែលមានរូបថតជុំគ្នាអីទេ

អឿក ៖ អត់ មិនដូចឥឡូវ យើងបេះថតឲ្យគ្នាទុក ចុះមានអីថត កាលការអត់មានអីថត

ដារ៉ា ៖ ចុះកាលការលោកតាអត់មានអីថត

អឿក ៖ អត់ទេ ហើយឥឡូវការចំណេញតែអ្នកថតបានលុយច្រើន...

ដានី ៖ ចុះលោកតា តា អាន់ គាត់មនុស្សដូចថាអត្តចរិកគាត់មនុស្សយ៉ាងម៉េច ដូចថាស្លូត

អឿក ៖ ហេ អត្តចរិកស្លូតល្អ តាមខ្ញុំដឹង អត្តចរិកវាអត់ចេះឃោរឃៅអីទេ

ដានី ៖ ចុះលោកតារត់មកមោស្រុកកៀនស្វាយ មោស្រុកភូមិវិញមានបានជួបគាត់ម្តងអីដែរ មុនបែកគ្នា?

អឿក ៖ អត់ស្មោះ ប៉ាក់ហ្នឹងក៏អត់អាលីង បងសឿនហ្នឹងក៏អត់អាលីង អត់ជួប

ដារ៉ា ៖ ចុះលោកតាមានបានសួរនាំយាយ រុន អីដែរ?

អឿក ៖ សួរដែរ ចុះបើប្អូនហើយ មិនសួរយ៉ាងម៉េច

ដារ៉ា ៖ សួរនាំទៅបានព័ត៌មានយ៉ាងម៉េចដែរ?

អឿក ៖ ហ៊ឺ អត់ឃើញទេបង ព្រោះខ្ញុំមានជីដូនជីតាខ្ញុំនៅហ្នឹង ឲ្យតែទៅសួរ សួរគេលិច អត់ គេថាអីចឹង រកមិនឃើញ គេថាស្លាប់ក៏មិនដឹង សៀង វានៅស្រុកនេះដែរបាត់ក៏រកមិនឃើញ មិនដឹងជារត់ទៅស្លាប់នៅឯណាក៏មិនដឹង តែបើថាទៅបរទេសមិនលែងអីទេ ខ្ញុំយល់ទេណា ព្រោះខ្ញុំធ្លាប់ដឹង អ្នកទៅឆ្ងាយៗបានដំណឹងមៅវិញច្រើនណាស់ មិនបងប្អូនក្តី បងប្អូនក្តី រាប់អានខ្ញុំនៅកៀនស្វាយដល់គេដឹងថាខ្ញុំវាស្រួល គេឲ្យលុយខ្ញុំមោវិញ មោម្តងឲ្យ៥ម៉ឺនៗ គាត់ស្លាប់ហើយ តែនៅតែបងប្អូន ឥឡូវលែងឲ្យហើយ តាំងពីស្លាប់យាយហ្នឹងមោ លែងឲ្យតែម្តង យាយហ្នឹងជួយគិតទៅរឿងហូបចុកអី ហើយជួយប្រាប់ទៀតថា កុំថាបានមកពីខ្ញុំ ព្រោះខ្ញុំកាន់នៅឡូនសាទផង កាន់ហ្នឹងមិនមែនទេគ្រាន់តែយកបាយទឹកឲ្យគេ ឥឡូវគេថាត្រូវដឹកត្រី១គោន២គោនអីមោ ខ្ញុំលាក់ទុក១បាវទុកហូប ដល់ពេលមោផ្ទះយាយង៉ែតហ្នឹងខ្ញុំលបយកឲ្យ ហើយដល់គេនឹកគុណ ហើយកូនគាត់១នោះឈ្មោះជ្រុន អាំងស៊ីញ៉័រអណ្តូងប្រេងទៀតណាពីដើម ខ្ញុំថាក្មួយឯងកុំប្រាប់គេ បើគេសួរថាម៉េចទៅពូ ខ្ញុំថាធាក់ស៊ីក្លូ អីចឹងអឺ គេសួរនៅ ថានៅទេ កុំប្រាប់ បើម៉េចពូ បើប្រាប់គេយកទៅវៃចោលហើយលាបល់យោ ស្រាប់គេនឹកគុណហ្នឹង

ដារ៉ា ៖ នៅរស់ដល់រាល់ថ្ងៃដែរ

អឿក ៖ ជ្រុន, នៅ ប្រមូលបងប្អូនទៅអស់ សរសេរសំបុត្រឲ្យខ្ញុំប៉ុនណឹងថាសុំឲ្យម៉ែក្មេកប្រមូលបងប្អូនទាំងអស់ជាពិសេសក្រុម អញ្ជើញពូអឿកទៅផង ខ្ញុំអាណិតគាត់ណាស់ គាត់ចិត្តល្អ ខ្ញុំធានា៨ឆ្នាំឲ្យគាត់រៀនថែមទៀត ហើយប្រាប់ទៅផ្លូវនេះៗចូលទៅថៃគាត់នៅចាំកន្លែងនេះ

ដាក់ក្នុងអក្សរខ្មែរ ប៉ុនខ្ញុំអត់ទៅ កាលណុងខ្ញុំកូនពេកផ្ទះសុទ្ធតែឬស្សី បើមោផ្ទះអីចឹងគេរុះបាត់ ខ្ញុំមោកំសត់អត់អី ខ្ញុំមិនដែលក្រដល់ថ្នាក់ក្រជំនាន់ ប៉ុល ពត ក្រអាលីងដល់ថ្នាក់បាតដៃទទេ អាលីងស្មោះ ហើយងើបបានប៉ុនណឹង អានេះបានពីកូនទេ

ដានី : ផ្ទះពីមុនមោគេរុះដែរ?

អឿក : រុះ, ផ្ទះគូអាហ្នឹងលើកក្រោយគ្នាម៉ាខែ

ដានី : ចុះលោកតាកាលជំនាន់ហ្នឹង លោកតាមានតួនាទីកម្មាភិបាលអីដែរ ម៉េចផ្ទះគេរុះអីចឹង?

អឿក : យេ អាហ្នឹងហើយរុះខ្ទាំងនោះ... គេថាឯមិនជ្រះស្រឡះ ធ្វើម៉េចបើខ្ញុំនៅនោះ គេរុះអត់មានទទឹងគេបានទេ

ដានី : ចុះផ្ទះអ្នកផ្សេងៗ ផ្ទះយាយ បូ ផ្ទះយាយចែម

អឿក : ហូ អាលីង

ដានី : គេរុះដែរ?

អឿក : បាទ អាលីងតែម្តង ផ្ទះនេះអីកុំតែជាប់ក្មេងនៅអីដាក់ស្គរអី នៅតែម៉ាឆ្នាំទៀតអាល្មើងហើយ អាលីងតែម្តងនោះ

ដានី : ចុះស្រុកកំណើតលោកតានៅណាទៅ ស្រុកកំណើតកើតជា?

អឿក : ខ្ញុំនៅទទឹងថ្ងៃ

ដានី : ភូមិអីគេ ភូមិទទឹងថ្ងៃ?

អឿក : បាទ

ដានី : ភូមិទទឹងថ្ងៃ ឃុំដាងទង

អឿក : បាទ

ដានី : ស្រុកត្រាំកក, សព្វថ្ងៃរស់នៅភូមិអី?

អឿក : នមោ

ដានី : ភូមិនមោ

អឿក : បាទ ព្រំប្រទល់ជាប់គ្នា

ដានី : ឃុំដាងទងដែរ

អឿក : ដាងទងដែរ

ដានី : លោកតាសព្វថ្ងៃប្រកបមុខរបររកស៊ីអីដែរ?

អឿក ៈ ឥឡូវវាគ្មានរបរអី ចៅៗវាចាក់លូចាក់អីឲ្យ គេមោទិញលក់ទៅបាន១ពាន់២ពាន់ ហើយ អ្នកចាក់គេបានពីរបីពាន់ដូចគ្នាទៅ ប៉ុនបើច្រើនបានច្រើន....

ដានី ៈ លោកតាគ្រាន់តែអ្នកលក់

អឿក ៈ បាទ អ្នកលក់គ្រាន់ដឹងផ្លូវដឹក អ្នកលើកដឹកទៅជាមួយគ្នាទៅ តែកូនចៅ ផ្ទះហ្នឹងមួយ ផ្ទះនោះមួយ ហៅវាមោឲ្យលើកមោដាក់អីទៅ ករកើតមោពីកូនដែរទេ កូនបង្កើតឲ្យ វាធ្វើមេដាងតែម្តង

ដានី ៈ គាត់ធ្វើមេដាងនៅភ្នំពេញ?

អឿក ៈ វាធ្វើតែដំបូល ឧបមាអគារធំ រដ្ឋធ្វើអីចឹង វាទៅដាងឯងធ្វើខាងតែដំបូលទេ ចាក់សរសរ ចាក់អីរៀបក្រោមស្រេចតែគេទៅ

ដានី ៈ អីចឹងខ្ញុំអរគុណលោកតាដែលចំណាយពេលសំណេះសំណាល

(ចប់)